## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេចបន្តអាណត្តិ

## អាជ្ញាប័ណ្ណរួមលេខ ០៤៨ ឯអ

## ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣ សម្រាប់លោក ឆោម សុផៃ

## អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១


## អាជ្ញាប័ណ្ណរួមលេខ ០៤៨ ឯអ

## ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣ សម្រាប់លោក ឆោម សុផៃ


-យោងឯកសារអាជ្ញាប័ណ្ណលេខ០៤៨ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យលោក ឆោម សុផៃ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣

-យោងពាក្យស្នើសុំបន្តអាណត្តិអាជ្ញាប័ណ្ណរបស់លោក ឆោម សុផៃ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៥

-យោងរបាយការណ៍វាយតម្លៃលើសំណើសុំបន្តអាណត្តិអាជ្ញាប័ណ្ណរបស់នាយកដ្ឋានបញ្ញត្តិកម្មលេខ១៨៣-០៥-បក ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០០៥

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥ ដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៥

-យោងតាមការអនុម័តរបស់សម័យប្រជុំ អាជ្ញាធរអគ្គិសនីកម្ពុជា លើកទី៦០ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៥

## សម្រេច

ប្រការ១

ដោយលោក ឆោម សុផៃ បានកែលំអមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់ខ្លួនបានមួយភាគធំ ហើយត្រូវធ្វើការកែលំអច្រើនបន្ថែមទៀតនៅឆ្នាំបន្តបន្ទាប់ដើម្បីឱ្យស្របតាមល័ក្ខខ័ណ្ឌទូទៅនៃស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចកែសម្រួលអាជ្ញាប័ណ្ណរួមលេខ ០៤៨ ឯអ ចុះថ្ងៃ ទី១៨ ខែសីហា ឆ្នាំ២០០៣ ដែលបានផ្តល់ជូនលោក ឆោម សុផៃ ដោយបន្ត អាណត្តិអាជ្ញាប័ណ្ណចំនួន ៤ ឆ្នាំ ទៀត ។

ប្រការ២

អាណត្តិថ្មីរបស់អាជ្ញាប័ណ្ណនេះ មានរយៈពេល ៤ ឆ្នាំ គិតចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៥ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួលលើកលែងតែត្រូវដកហូត ដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។

ប្រការ៣

សេចក្តីសម្រេចនេះ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៤៨ ឯអ ។

ប្រការ៤

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៤៨ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។

ប្រការ៥

សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ៦

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេច នេះទៅតម្កល់ទុកបន្ថែមនៅតាម ទីកន្លែង ដែលឯកសារអាជ្ញាប័ណ្ណលេខ ០៤៨ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ០៤៨ឯអ ដែលតម្កល់មានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៥

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

# ឧបសម្ព័ន្ធទី២
# មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ

## ក_មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ

### រោងម៉ាស៊ីន

១- ទីតាំងម៉ាស៊ីនរបស់អ្នកកាន់អាជ្ញាប័ណ្ណ ស្ថិតក្នុងភូមិដំដែកផ្សារ ឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

### លក្ខណៈទូទៅនៃម៉ាស៊ីន

១- អ្នកកាន់អាជ្ញាប័ណ្ណ មានម៉ាស៊ីនភ្លើងចំនួន ០៣គ្រឿង ដែលមានអានុភាព តំឡើងសរុប 200kVA គឺ:

- ម៉ាស៊ីនលេខ១ អានុភាព 125kVA
- ម៉ាស៊ីនលេខ២ អានុភាព 40kVA
- ម៉ាស៊ីនលេខ៣ អានុភាព 35kVA

២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងម៉ាស៊ូត ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៩.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។